**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ១ករណីថ្មីទៀត ជាជនជាតិបារាំង អាយុ ៣៥ ឆ្នាំ នៅរាជធានីភ្នំពេញ

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា មាន **បុរសជនជាតិបារាំង អាយុ ៣៥ ឆ្នាំ ម្នាក់ពិជ្ជមានវីរុសកូវីដ១៩ ៖**

- គាត់ មានប្រពន្ធ និងកូនប្រុសអាយុ៤ខែ (សរុបគ្នា៣នាក់) ហោះហើរចេញពីទីក្រុងប៉ារីសនៃប្រទេសបារាំងទៅដល់សាំងហ្គាពួរនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០
- ដោយបុរសអាយុ ៣៥ ឆ្នាំ ខាងលើនេះ មានអាការៈក្តៅខ្លួន អាជ្ញាធរសាំងហ្គាពួរ បានធ្វើតេស្តសំណាកវត្ថុវិភាគរបស់គាត់នៅយប់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ នោះ
- ក្នុងពេលរង់ចាំលទ្ធផល គ្រូពេទ្យសាំងហ្គាពួរបានជម្រាបគាត់ថាមិនឲ្យធ្វើដំណើរទៅណាទៀតទេ រង់ចាំរហូតដល់មានលទ្ធផលសិន។ តែនៅពេលមានអ្នកប្តូរវេនតាមដានសុខភាពគាត់ រូបគាត់ក៏ត្រូវបានគេជម្រាបថាគាត់អាចធ្វើដំណើរបាន រីឯលទ្ធផលអាចផ្តល់ជូននៅតាមក្រោយបាន (តាមការបញ្ជាក់របស់សាមីខ្លួន)
- បុរសអាយុ ៣៥ ឆ្នាំ ដែលមិនទាន់បានលទ្ធផលតេស្តនៅសាំងហ្គាពួររូបនោះ ក៏បានហោះហើរចេញមកទីក្រុងភ្នំពេញ តាមជើងហោះហើរសាំងហ្គាពួរ MI 602 នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០ មកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅម៉ោង៨:៣០ព្រឹក។ ពេលធ្វើដំណើរគាត់បានប្រាប់ថា គាត់បានពាក់ម៉ាស់ ហើយអត់មានក្តៅខ្លួនទេនៅពេលនោះ ហើយក៏បានមកដល់ផ្ទះប្រហែលជាម៉ោង១០ព្រឹកនៃថ្ងៃដដែល
- ក្រោយពីចេញលទ្ធផលតេស្តរបស់គាត់ វិជ្ជមានវីរុសកូវីដ១៩ពីសាំងហ្គាពួរ នារសៀលថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០ ក្រសួងសុខាភិបាល បានទទួលព័ត៌មានពីករណីនេះ ហើយក្រសួងក៏បានស្រាវជ្រាវភ្លាមៗរកឃើញបុរសរូបនេះនៅវេលាម៉ោង២០:៣០នាទីយប់នៃថ្ងៃដដែល។ បន្ទាប់មក ក្រុមគ្រូពេទ្យក៏បានយកសំណាកវត្ថុវិភាគរបស់គាត់ ប្រពន្ធ និងកូនគាត់ នៅវេលាម៉ោង២១:៣០នាទីយប់នៃថ្ងៃដដែល។
- ភរិយា និងកូនបុរសជនជាតិបារាំងអាយុ ៣៥ ឆ្នាំ រូបនេះ ត្រូវដាក់នៅបន្តតាមដានសុខភាពក្នុងរយៈពេល១៤ថ្ងៃ នៅផ្ទះរបស់ប្អូនគាត់ នៅម្តុំសង្កាត់ទួលទំពូង រាជធានីភ្នំពេញ ក្នុងពេលរង់ចាំលទ្ធផលវិភាគ

សំណាករបស់ពួកគាត់ ពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

- លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅវេលាម៉ោង១៤:៣០នាទីរសៀលនៃថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ បានបង្ហាញថា **បុរសជនជាតិបារាំងអាយុ ៣៥ ឆ្នាំ វិជ្ជមានវីរុសកូវីដ១៩** រីឯ ភរិយា និងកូនរបស់គាត់ តម្រូវឲ្យមានការរង់ចាំលទ្ធផលបន្តទៀតសិន។ បច្ចុប្បន្ននេះ បុរសជនជាតិបារាំងអាយុ ៣៥ ឆ្នាំ រូបនេះ ត្រូវបានដាក់ឲ្យនៅសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រួចហើយ
- ក្រុមការងារក្រសួងសុខាភិបាល បាននិងកំពុងស្រាវជ្រាវអ្នកដែលប៉ះពាល់ ហើយបានរកឃើញ៖
    - អ្នកនៅលើយន្តហោះ ចំនួន ៨ នាក់ សុទ្ធសឹងជាជនបរទេស បានសំចតរង់ចាំតជើងហោះហើរ (Transit) ទៅប្រទេសផ្សេងៗ តែមិនមានចូលមកកម្ពុជាទេ។
    - សរុបអ្នកនៅលើយន្តហោះមកភ្នំពេញ មានចំនួន ២៤ នាក់ (រាប់ទាំងពួកគាត់៣នាក់ផងដែរ) និងបុគ្គល ២ នាក់ផ្សេងទៀតជាអ្នកទំនាក់ទំនងនឹងដឹកពួកគាត់ទៅផ្ទះ ដូច្នេះ សរុប ២៦នាក់

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ៧រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា